00284965

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 03 / 03 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

D 138

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 03 / 03 / 2009
ម៉ោង (Time/Heure): 9:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**

សំណុំរឿងព្រហ្មទណ្ឌ
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**
**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 002/19-09-2007-ECCC-OCIJ**

# ដីកាសម្រេចអំពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ

# Order on breach of confidentiality of judicial investigation

# Ordonnance sur violation du secret de l'instruction

យើង **យូ ប៊ុនឡេង** និង **Marcel LEMONDE** សហចៅក្រមស៊ើបអង្កេតនៃអង្គ ជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក.")

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពី អ.វ.ត.ក.")

បានឃើញការបើកការស៊ើបសួរលើឈ្មោះ **អៀង សារី** និង **ជនផ្សេងទៀត** ទាក់ទងនឹងបទចោទប្រកាន់អំពី**បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** និង**ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩** បទល្មើសដែលមានចែង និងផ្តន្ទាទោស តាមមាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពី អ.វ.ត.ក.

បានឃើញវិធាន ៣៥ ៣៨ និង ៥៦ នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក. ("វិធានផ្ទៃក្នុង")



CO-INVESTIGATING JUDGES ECCC

បានឃើញមាត្រា ៣.១២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក. ចុះថ្ងៃទី ១០ ខែតុលា ឆ្នាំ ២០០៨ ("សេចក្តីណែនាំអនុវត្ត")

**ការរំលឹកឡើងវិញអំពីអង្គហេតុ និងនីតិវិធី**

១. នាថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ ២០០៨ បន្ទាប់ពីមានការបោះផ្សាយនូវអត្ថបទរបស់សារព័ត៌មាន *"The Cambodia Daily"* ក្រោមចំណងជើងថា *"Noun Chea seeks Evidence from Foreign Powers"* ដែលខ្លឹមសារនៃអត្ថបទនោះមាននិយាយពាក់ព័ន្ធដល់ព័ត៌មានសម្ងាត់នៃកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតបានផ្ញើជាលិខិតមួយទៅកាន់គ្រប់ក្រុមមេធាវីការពារក្តីទាំងអស់ (A238) ដោយបានធ្វើការរំលឹកភាគីនៃរឿងក្តីអំពីកាតព្វកិច្ចក្នុងការរក្សាការសម្ងាត់ ដែលពួកគេត្រូវគោរព។

> ខ្លឹមសារនៃលិខិតនោះមានជាអាទិ៍៖
> *"ភាពសម្ងាត់នៃកិច្ចស៊ើបសួរ គឺជាបញ្ហាមួយដែលអាចត្រូវលើកលែងបានដោយយុត្តាធិការដែលមានសមត្ថកិច្ចតែប៉ុណ្ណោះ...ហើយសហចៅក្រមស៊ើបអង្កេត នៅពេលនេះមិនទាន់ធ្វើសេចក្តីសម្រេចបែបនេះនៅឡើយទេ...យើងសូមឆ្លៀតយកឱកាសនេះបញ្ជាក់ច្បាស់ពី ភាពសម្ងាត់នៃសំណុំរឿងស៊ើបអង្កេត និងជាពិសេស សូមរំលឹកដល់លោក-លោកស្រីថា ទោះបីជាភាគីមួយជាអ្នកដាក់សារណាទៅក្នុងសំណុំរឿងក៏ដោយ ក៏ភាគីនោះមិនអាចផ្សព្វផ្សាយវាជាសាធារណៈ ឬក៏លាតត្រដាងឲ្យដឹងថាឯកសារទាំងនោះត្រូវបានដាក់ទៅក្នុងសំណុំរឿងបានដែរ។"*

២. បន្ទាប់ពីមានកិច្ចប្រជុំកាលពីថ្ងៃទី ១១ ខែធ្នូ ឆ្នាំ ២០០៨ រវាងក្រុមមេធាវីការពារក្តី អៀង សារី ("ក្រុមមេធាវីការពារក្តី") និងលោក Knut ROSANDHAUG ដែលជាអនុប្រធានការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក. ក្រុមមេធាវីការពារក្តីបានធ្វើលិខិតមួយច្បាប់ជូនលោក Rosandhaug នៅថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០០៨ និងបានចម្លងជូនទៅបុគ្គល និងស្ថាប័ននានា ដែលក្នុងនោះមានការិយាល័យសហចៅក្រមស៊ើបអង្កេតផងដែរ។ នៅក្នុងលិខិតនោះ ក្រុមមេធាវីការពារក្តីបានលើកឡើងថា៖

*"ដើម្បីបង្ហាញពីការប្តេជ្ញាចិត្តរបស់យើងខ្ញុំចំពោះដំណើរការប្រកបដោយយុត្តិធម៌ និងតម្លាភាព នៅអង្គជំនុំជម្រះវិសាមញ្ញ យើងខ្ញុំសូមគូសបញ្ជាក់ឡើងវិញនូវចេតនារបស់យើង ដែលបានសម្តែងនៅឯកិច្ចប្រជុំដើម្បីបង្កើតគេហទំព័រ (website) មួយសម្រាប់ផ្តល់ព័ត៌មានទាក់ទងនឹងឯកសារសាធារណៈទាំងអស់ ដែលដាក់ដោយក្រុមមេធាវីការពារក្តីរបស់លោក អៀង សារី។ ការអនុវត្តន៍បច្ចុប្បន្នដោយអង្គជំនុំជម្រះ និងសហចៅក្រមស៊ើបអង្កេតនៅអង្គជំនុំជម្រះវិសាមញ្ញ ដែលកំពុងដាក់សំពាធលើការដាក់ឯកសាររបស់មេធាវីការពារ ដែលអាចធ្វើឱ្យអាម៉ាស ឬដែលអាចឈានទៅរកការចោទជាបញ្ហាដល់ភាពស្របច្បាប់ និងកិច្ចការរបស់តុលាការ (judiciousness of acts) និងសេចក្តីសម្រេចយ៉ាងហួត់ចត់របស់ចៅក្រម ដែលអ្វីៗទាំងអស់ប្រៀបបានដូចជាផ្លែល្វា (fig leaf) ដែលល្អតែសំបកក្រៅ ដែលកត្តាទាំងអស់នេះគឺជាវិធានការចាំបាច់ដើម្បីការពារអ្វីដែលហៅថាភាពសម្ងាត់ និងសុច្ចរិតភាពនៃការស៊ើបអង្កេត ឬដំណើរការធ្វើសេចក្តីសម្រេច ត្រូវតែបញ្ឈប់ដោយគ្មានលក្ខខណ្ឌ។ សារណាទាំងអស់ដែលជាកិច្ចការរបស់មេធាវីការពារក្តី ហើយមិនជាប់ពាក់ព័ន្ធជាមួយដំណើរការស៊ើបអង្កេតអង្គហេតុដែលកំពុងតែបន្ត ប៉ុន្តែជាប់ពាក់ព័ន្ធតែជាមួយបញ្ហាច្បាប់ ត្រូវតែបានពិភាក្សាក្រោមការឃ្លាំមើលរបស់សាធារណៈជន។ ដើម្បីអនុញ្ញាតឱ្យមានការពិភាក្សាជាសម្ងាត់លើបញ្ហាដែលមិនមែនសម្ងាត់ វាមិនត្រឹមតែដកហូតសិទ្ធិរបស់លោក* ***អៀង សារី*** *ក្នុងការទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ និងជាសាធារណៈប៉ុណ្ណោះទេ តែថែមទាំងបានរារាំងប្រទេសកម្ពុជាក្នុងការបង្ហាញថា ការជំនុំជម្រះលើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ មានលក្ខណៈស្មុគ្រស្មាញ អាចប្រព្រឹត្តទៅដោយចំហរ និងតម្លាភាពទៀតផង។"*

៣. នាថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០០៩ ការិយាល័យសហចៅក្រមស៊ើបអង្កេតបានផ្ញើលិខិតមួយច្បាប់ជូនដល់ក្រុមមេធាវីការពារក្តី (A238/1/Corr.1) ដោយបានធ្វើការបញ្ជាក់ថា៖

*"សហចៅក្រមស៊ើបអង្កេតសូមធ្វើការរំលឹកថា ការរក្សាការសម្ងាត់នៃឯកសារសំណុំរឿងដែលកំណត់ដោយវិធានផ្ទៃក្នុង ត្រូវអនុវត្តចំពោះគ្រប់ការដាក់ឯកសារទាំងអស់ រួមបញ្ចូលទាំងឯកសារដែលដាក់ដោយភាគីផងដែរ...។ ដូចធ្លាប់បានបញ្ជាក់ប្រាប់ពីមុនរួចមកហើយថា*

*វាគឺសិទ្ធិអំណាចរបស់ចៅក្រម មិនមែនរបស់ភាគីទេ ក្នុងការសម្រេចថាតើពេលណា ឬដោយរបៀបណា ដែលត្រូវបើកបង្ហាញឯកសារសំណុំរឿងជាសាធារណៈនោះ។"*

៤. នាថ្ងៃទី ២០ ខែមករា ឆ្នាំ ២០០៩ ក្រុមមេធាវីការពារក្ដីបានបញ្ជាក់អំពីការបានទទួលនូវលិខិតចុះថ្ងៃទី ១៥ មករា និងបានធ្វើការឆ្លើយតបមកវិញ (A238/2)។ ទោះបីជាមានការបដិសេធយ៉ាងច្បាស់លាស់ពីសំណាក់សហចៅក្រមស៊ើបអង្កេតទៅហើយក្ដី ក៏ពួកគេនៅតែអះអាងថា ពួកគេមានសេរីភាពក្នុងការចែកផ្សាយឯកសារសំណុំរឿងយោងតាមទំនើងចិត្តរបស់ពួកគេ។ នៅក្នុងកថាខណ្ឌទី ៤ ក្រុមមេធាវីការពារក្ដីបានធ្វើការឆ្លើយតបថា៖

> *"គួរកត់សម្គាល់ផងដែរថា នៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និងរ្វ៉ាន់ដា គេហទំព័រនានាត្រូវបានប្រើប្រាស់ដោយក្រុមមេធាវីការពារក្ដី ដែលប្រកបវិជ្ជាជីវៈនៅតុលាការទាំងនេះ ដើម្បីផ្សព្វផ្សាយនូវការដាក់ឯកសាររបស់ពួកគេ។ ការប្រើប្រាស់គេហទំព័រនេះបានកើតមានឡើងទាំងនៅដំណាក់កាលមុនសវនាការ ដែលស្រដៀងគ្នានឹងដំណាក់កាលស៊ើបសួរដែរ និងរហូតដល់ដំណាក់កាលសវនាការ។ ការប្រើប្រាស់គេហទំព័របែបនេះហាក់ដូចជាមិនបានបង្ករការលំបាកណាមួយដល់តុលាការដែលពាក់ព័ន្ធទាំងពីរខាងលើនេះទេ។*

៥. នាថ្ងៃទី ២៦ ខែមករា ឆ្នាំ ២០០៩ គឺជាង ១០ ថ្ងៃ បន្ទាប់ពីទទួលបានលិខិតរបស់ ក.ស.ច.ស. ដែលរំលឹកដល់ក្រុមមេធាវីការពារក្ដីអំពីកាតព្វកិច្ចតាមផ្លូវច្បាប់របស់ពួកគេ ក្រុមមេធាវីការពារក្ដីបានធ្វើការផ្សាយនៅលើគេហទំព័ររបស់ខ្លួននូវឯកសារសំណុំរឿងចំនួន ០៩ ច្បាប់ ដែលទង្វើបែបនេះមិនធ្លាប់បានទទួលការអនុញ្ញាតពីសំណាក់ចៅក្រមនោះទេ។

**<u>ច្បាប់ដែលត្រូវអនុវត្ត</u>**

៦. វិធាន ៥៦ នៃវិធានផ្ទៃក្នុង ដែលត្រូវអនុវត្តចំពោះគ្រប់ជនទាំងអស់ ដែលចូលរួមនៅក្នុងកិច្ចស៊ើបសួរ ជាពិសេសចំពោះមេធាវីរបស់ភាគី ចែងថា៖



CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION* ECCC * CETC

"១.	ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគី ការស៊ើបសួរមិនត្រូវធ្វើឡើងជាសាធារណៈឡើយ។ បុគ្គលទាំងអស់ដែលចូលរួមក្នុងការស៊ើបសួរត្រូវរក្សាឱ្យបាននូវការសម្ងាត់។

២.	ក៏ប៉ុន្តែសហចៅក្រមស៊ើបអង្កេតអាចៈ

ក-តាមរយៈផ្នែកកិច្ចការសាធារណៈ ផ្តល់ដោយរួមគ្នានូវព័ត៌មានពាក់ព័ន្ធទៅនឹងសំណុំរឿងដែលកំពុងស្ថិតនៅក្នុងការស៊ើបសួរ ប្រសិនបើយល់ឃើញថាជាការចាំបាច់ ដើម្បីធ្វើឱ្យសាធារណៈជនបានដឹងអំពីកិច្ចដំណើរការនីតិវិធី ឬ ដើម្បីកែតម្រូវព័ត៌មានមិនពិត ឬព័ត៌មាននាំឱ្យមានការភ័ន្តច្រឡំ។

ខ-ក្នុងកាលៈទេសៈពិសេស ផ្តល់ការអនុញ្ញាតដោយរួមគ្នាដល់សារព័ត៌មាន ឬ អ្នកដទៃទៀតដែលមិនមែនជាភាគីឱ្យចូលរួមដោយមានកំរិតនៅក្នុងកិច្ចស៊ើបសួរ ដោយការចូលរួមនេះត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យដ៏តឹងរ៉ឹងរបស់ខ្លួន និង បន្ទាប់ពីបានសួរយោបល់របស់ភាគីនៅក្នុងកិច្ចដំណើរការនីតិវិធីនេះ។ ក្នុងករណីមិនគោរពទៅតាមល័ក្ខខ័ណ្ឌណាមួយដែលសហចៅក្រមស៊ើបអង្កេតតម្រូវ វិធាន ៣៥ ដល់ ៣៨ ត្រូវយកមកអនុវត្ត។"

៧. មាត្រា ៣.១២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ បានបញ្ជាក់បន្ថែមថា៖

"ភាគីដែលដាក់ឯកសារអាចបង្ហាញពីសំណូមពររបស់ខ្លួនដើម្បីដាក់ឯកសារនោះត្រូវគេកំណត់អត្ថបទ"សាធារណៈ" "សំងាត់"ឬ"បិទស្លាកបោះត្រា" ។ មានតែសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំបុរេជម្រះប៉ុណ្ណោះ ដែលមានអំណាចពិនិត្យមើលឯកសារដើម្បីកំណត់ថាតើការកំណត់ប្រភេទនៃអត្ថបទទាំងនោះមានលក្ខណៈសមស្រប ឬទេ ។សេចក្តីសម្រេចណាមួយអំពីបញ្ហានេះរបស់សហចៅក្រមស៊ើបអង្កេត ឬ អង្គបុរេជំនុំជម្រះត្រូវមានអានុភាពអនុវត្តក្នុងអំឡុងពេលនៃសវនាការបន្តបន្ទាប់ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងមានអំណាចដោយគំនិតផ្តួចផ្តើមខ្លួនឯងឬ ទៅតាមពាក្យស្នើសុំរបស់ភាគី ក្នុងការកែប្រែសេចក្តីសម្រេចនោះមួយផ្នែកឬទាំងមូល ក្រោយពីបានជូនដំណឹងទៅភាគីដែលទទួលឥទ្ធិពលនៃសេចក្តីសម្រេចនេះ និងផ្តល់អោយភាគីនូវសិទ្ធិចូលរួមក្នុងសវនាការ ។"

៨. វិធាន ៣៥ នៃវិធានផ្ទៃក្នុងទាក់ទងនឹង "ការជ្រៀតជ្រែកចូលក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ" ចែងថា៖

*"១. អង្គជំនុំជម្រះវិសាមញ្ញអាចដាក់ទណ្ឌកម្ម ឬ បញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចនូវជនណាម្នាក់ដែលជ្រៀតជ្រែកដោយចេតនាពិតប្រាកដ ក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ រួមទាំងបុគ្គលដែលមានចែងដូចខាងក្រោមៈ*

*ក-ផ្សាយចេញព័ត៌មានសម្ងាត់ ដោយរំលោភទៅនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំ ជម្រះ។ (...)*

*៥. ប្រសិនបើរកឃើញថា មេធាវីណាម្នាក់បានប្រព្រឹត្តអំពើណាមួយដូចមានចែងក្នុងអនុវិធាន ១ ខាងលើ សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះដែលរកឃើញកំហុសនោះ អាចកំណត់ថាការប្រព្រឹត្តអំពើនេះគឺជាកំហុសវិជ្ជាជីវៈរបស់មេធាវី ដូចមានចែងក្នុងវិធាន ៣៨។"*

៩. វិធាន ៣៨ នៃវិធានផ្ទៃក្នុង ដែលនិយាយអំពី "កំហុសវិជ្ជាជីវៈរបស់មេធាវី" ចែងថា៖

*"១. សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ក្រោយពេលព្រមាន អាចដាក់ទណ្ឌកម្ម ឬបដិសេធក្នុងការចូលរួមសវនាការចំពោះមេធាវីណាមួយ ប្រសិនបើយល់ឃើញថា ការប្រព្រឹត្តរបស់មេធាវីរូបនោះ ជាការប្រមាថមើលងាយ រាំងស្ទះដល់កិច្ចដំណើរការនីតិវិធី រំលោភទៅលើរឿងក្តី ឬ ផ្ទុយទៅនឹងមាត្រា ២១-៣ នៃកិច្ចព្រមព្រៀង។*

*២. សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះអាចបញ្ជូនករណីកំហុសវិជ្ជាជីវៈនេះទៅអង្គភាពមានសមត្ថកិច្ច។"*

១០. ជាចុងបញ្ចប់ យោងតាមមាត្រា ២១(៣) នៃកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក.៖

*"មេធាវីណាដែលមានសញ្ជាតិខ្មែរ ឬមិនមែនខ្មែរ ដែលត្រូវជួល ឬចាត់តាំងឲ្យធ្វើការជាមួយជនសង្ស័យ ឬជនជាប់ចោទក្នុងការការពារក្ដីរបស់ខ្លួន ត្រូវអនុវត្តតាមកិច្ច ព្រមព្រៀងនេះ ច្បាប់កម្ពុជាស្តីពីលក្ខន្តិកៈមេធាវី បទដ្ឋាន និងសីលធម៌នៃវិជ្ជាជីវៈច្បាប់ដែលគេទទួលស្គាល់។"*



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * ECCC * CETC

00284971

## <u>សំអាងហេតុនៃសេចក្តីសម្រេច</u>

១១. ជាបឋម សូមធ្វើការរំលឹកថា ទោះក្នុងកាលៈទេសៈបែបណាក៏ដោយ ក៏គោលការណ៍នៃការសម្ងាត់នៃកិច្ចស៊ើបសួរមិនអាចនឹងធ្វើឲ្យប៉ះពាល់ដល់សិទ្ធិរបស់ជនត្រូវចោទ ក្នុងការបានទទួលនូវការជំនុំជម្រះប្រកបដោយយុត្តិធម៌នោះទេ ក្នុងខណៈដែលវាទាក់ទងទៅតែនឹងដំណាក់កាលដំបូងនៃនីតិវិធីតែប៉ុណ្ណោះ ហើយវាមិនត្រូវបានគេអនុវត្តទេក្នុងដំណាក់កាលជំនុំជម្រះ។ ការជំនុំជម្រះក្តីអាចជាការជំនុំជម្រះក្តីមួយប្រកបដោយយុត្តធម៌បាន ប្រសិនបើ បន្ទាប់ពីមានកិច្ចស៊ើបសួរជាលក្ខណៈសម្ងាត់មកសវនាការជាសាធារណៈមួយត្រូវបានគេរៀបចំឡើង ដែលក្នុងពេលនោះក្រុមមេធាវីការពារក្តីមានគ្រប់លទ្ធភាពទាំងអស់ក្នុងការបដិសេធភស្តុតាងនានា ដែលទទួលបាន។ ដើម្បីធ្វើការវាយតម្លៃអំពីចរិតលក្ខណៈយុត្តិធម៌របស់ការជំនុំជម្រះក្តី យើងត្រូវពិនិត្យទៅលើទិដ្ឋភាពទាំងមូលនៃនិតិវិធី[1]។

១២. យោងលើបទប្បញ្ញត្តិនៃវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្ត ដែលបានរៀបរាប់ខាងលើ វាមានលក្ខណៈច្បាស់លាស់ហើយដែលថា ការសម្ងាត់នៃនីតិវិធីត្រូវអនុវត្តលើគ្រប់ឯកសារទាំងអស់ រួមទាំងឯកសារដែលតាក់តែងឡើងដោយភាគីផងដែរ ហើយវាគឺជាឆន្ទានុសិទ្ធិរបស់ចៅក្រមតែមួយគត់ក្នុងការកំណត់ថាតើ នៅពេលណា និងយ៉ាងដូចម្តេច ដែលត្រូវផ្សព្វផ្សាយឯកសារសម្ងាត់នៃសំណុំរឿងនោះ។ សេចក្តីសម្រេចក្នុងផ្សព្វផ្សាយត្រូវធ្វើឡើងដោយពិចារណាទៅលើលក្ខណៈវិនិច្ឆ័យសត្យានុម័ត ដែលមានដូចជា ការរក្សាសិទ្ធិ និងផលប្រយោជន៍របស់ភាគី ការការពារសាក្សី និងជនរងគ្រោះ ឬភាពមិនលំអៀងនៃកិច្ចស៊ើបសួរជាដើម និងក៏ត្រូវពិចារណាទៅលើកាលវិភាគការងារស៊ើបសួរផងដែរ[2]។

---

[1] តុលាការសិទ្ធិមនុស្សអឺរ៉ុប Barbera, Messegue និង Jarbardo ទល់នឹង ប្រទេសអេស្ប៉ាញ សាលដីកាចុះថ្ងៃទី ០៦ ធ្នូ ១៩៨៨ serie A លេខ 146 កថា ៦៨។ សូមមើលផងដែរ៖ តុលាការសិទ្ធិមនុស្សអឺរ៉ុប Berkouche ទល់នឹង ប្រទេសបារាំង ២៤ សីហា ២០០៥ កថា. ៥៣។ តុលាការសិទ្ធិមនុស្សអឺរ៉ុប Delta ទល់នឹង ប្រទេសបារាំង ១៩ ធ្នូ ២០០៨ កថា. ៣៦ ដែលបានយោងទៅដល់ តុលាការសិទ្ធិមនុស្សអឺរ៉ុប Kostovski ទល់នឹង ប្រទេសហូឡង់ ២០ វិច្ឆិកា ១៩៨៩ serie A លេខ ១៦៦ កថា. ៤១។ តុលាការសិទ្ធិមនុស្សអឺរ៉ុប Unterpertinger ទល់នឹង ប្រទេសអូទ្រីស ២៤ វិច្ឆិកា ១៩៨៦ serie A លេខ ១១០ កថា. ៣១។

[2] ដើម្បីធ្វើការកំណត់អំពីកាលវិភាគការងារស៊ើបសួរនេះ ចៅក្រមត្រូវពិចារណាទៅលើកត្តាជាច្រើន ជាពិសេសសំណើសុំរបស់គ្រប់ក្រុមមេធាវីការពារក្តីទាំងអស់ របស់សហព្រះរាជអាជ្ញា និងរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងព្រមទាំងតាម



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

00284972



ជាច្រើនដងច្រើនសារមកហើយ ដែលសហចៅក្រមស៊ើបអង្កេតបានធ្វើការរំលឹកយ៉ាងច្បាស់លាស់ទៅដល់ភាគីអំពីកាតព្វកិច្ចរបស់ពួកគេចំពោះបញ្ហានេះ[3]។

១៣. ក្រុមមេធាវីការពារក្តីមិនអាចនឹងលើកឡើងអំពីការមិនស្គាល់ ឬមិនយល់របស់ខ្លួនអំពីប្រព័ន្ធច្បាប់រ៉ូម៉ាំង (romano-germanique) ដែលអនុវត្តនៅ អ.វ.ត.ក. ឬក៏បង្ហាញពីការមិនយល់ព្រមរបស់ខ្លួនទាក់ទងនឹងគោលការណ៍រក្សាការសម្ងាត់នៃកិច្ចស៊ើបសួរ ដើម្បីជាការជំទាស់ទៅនឹងអនុភាពគតិយុត្តិនៃបទប្បញ្ញត្តិនៃវិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត ឬរាល់សេចក្តីសម្រេច[4] ដែលចេញដោយចៅក្រមនៃស្ថាប័ននេះបានទេ ឬក៏ដើម្បីរួចផុតអំពីចំណងកាតព្វកិច្ចវិជ្ជាជីវៈដែលខ្លួនត្រូវបំពេញនោះបានដែរ។

១៤. ប្រសិនបើខ្លួនមានការព្រួយបារម្ភអំពីតម្លាភាព ក្រុមមេធាវីការពារក្តីគួរតែស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតធ្វើការផ្សព្វផ្សាយឯកសារជាសាធារណៈ ប្រសិនបើខ្លួនយល់ថាការផ្សព្វផ្សាយនោះវាមានសារៈសំខាន់ដល់ការយល់ដឹងរបស់សាធារណៈអំពីនីតិវិធីតុលាការ។ ផ្ទុយទៅវិញ ជំនួសដោយការស្នើសុំនេះ ក្រុមមេធាវីការពារក្តីបានសរសេរជាលិខិតមួយច្បាប់ ផ្ញើជូនទៅអនុប្រធានការិយាល័យរដ្ឋបាល (ដែលរូបគាត់មិនមានសមត្ថកិច្ចក្នុងធ្វើការកំណត់ថាតើ ឯកសារផ្នែកណាមួយនៃកិច្ចស៊ើបសួរអាចត្រូវនឹងបានបើកចំហរជាសាធារណៈនោះទេ) ដោយក្នុងលិខិតនោះ ក្រុមមេធាវីការពារក្តីបានបង្ហាញអំពីឆន្ទៈរបស់ខ្លួនក្នុងការបោះផ្សាយជាសាធារណៈ និងជាឯកតោភាគី នូវឯកសារទាំងឡាយណាដែលខ្លួនយល់ថាសមស្រប។

---

រយៈការផ្តួចផ្តើមរបស់ខ្លួនចៅក្រមផ្ទាល់ផងដែរ។ វិធាន ៥៥(១០) នៃវិធានផ្ទៃក្នុងចែងថា សហចៅក្រមស៊ើបអង្កេត ក្នុងករណីដែលបដិសេធបំពេញកិច្ច ត្រូវចេញដីកាបដិសេធ “ឱ្យឆាប់បំផុតតាមដែលអាចធ្វើបាន និងយ៉ាងយូរបំផុតឲ្យបានមុនពេលបិទការស៊ើបសួរ”។ វិធាននេះមិនមានចែងបញ្ញត្តិដែលមានលក្ខណៈស្រដៀងគ្នា ទៅនឹងបញ្ញត្តិខាងលើនេះទេ ក្នុងករណីដែលសំណើសុំត្រូវបានទទួលយក។

[3] សូមមើល កថា.១ និង ៣ ខាងលើ។

[4] ប្រសិនបើ នៅក្នុងករណីនេះ សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត មានទំរង់ជាលិខិតធម្មតា យុត្តិសាស្ត្ររបស់ អ.វ.ត.ក. បានបញ្ជាក់ច្បាស់លាស់ហើយថា គឺខ្លឹមសារនៃលិខិត ដែលជាកត្តាកំណត់ថា តើកិច្ចនេះជាសេចក្តីសម្រេច ឬយ៉ាងណា គឺមិនមែនទំរង់នៃលិខិតជាកត្តាកំណត់នោះទេ *(សូមមើលសេចក្តីសម្រេចទាក់ទងនឹងការទទួលយកបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ស្តីអំពីសិទ្ធិចូលសួរសុខទុក្ខ ចុះថ្ងៃទី ២១ មីនា ២០០៨)*។

១៥. ក្រុមមេធាវីការពារក្ដីបានអះអាងថា សហចៅក្រមស៊ើបអង្កេតអាចនឹងមានលទ្ធភាពលុបចោលនូវ *"រាល់ឯកសាររបស់មេធាវីការពារ ដែលអាចធ្វើឱ្យអាម៉ាស់ ឬដែលអាចឈានទៅរកការចោទជាបញ្ហាដល់ភាពស្របច្បាប់ និងភាពត្រឹមត្រូវនៃកិច្ចការតុលាការ (judiciousness of acts) ក្រោមហេតុផលថា ទាំងនេះគឺជាវិធានការណ៍ចាំបាច់សម្រាប់ធានា ការពារអ្វីដែលហៅថាភាពសម្ងាត់ និងបូរណភាពនៃកិច្ចស៊ើបសួរ ឬធានាដល់ដំណើរការនៃការធ្វើសេចក្ដីសម្រេចរបស់តុលាការ"* ។ ការចោទប្រកាន់បែបនេះមានលក្ខណៈធ្ងន់ធ្ងរ និងគ្មានមូលដ្ឋាន។ ឧទាហរណ៍ថា បើទោះបីជាការចោទប្រកាន់នេះត្រឹមត្រូវក៏ដោយ ក៏ក្រុមមេធាវីការពារក្ដីនឹងមិនមានអំណាចក្នុងការអនុញ្ញាតឱ្យខ្លួនឯងមានសិទ្ធិក្នុងការសម្រេចជាឯកតោភាគីថាតើ ឯកសារណា ដែលត្រូវផ្សព្វផ្សាយជាសាធារណៈនោះដែរ។

១៦. ជាងនេះទៅទៀត ទឡ្ហីករណ៍នៃ "តម្លាភាព" មិនមានលក្ខណៈត្រឹមត្រូវទេ បើសិនជាយើងធ្វើការវិភាគលើអង្គហេតុមួយចំនួន ដែលកើតចេញពីព្រឹត្តិការណ៍ថ្មីៗ កន្លងទៅនេះ។ ជាក់ស្ដែង នាថ្ងៃសុក្រ ទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០៩ ក្រុមមេធាវីការពារក្ដីបានដាក់សំណើនៅចំពោះមុខអង្គបុរេជំនុំជម្រះ *សំណើរបស់ អៀង សារី សុំឱ្យមានការដាក់បញ្ចូលទៅក្នុង សំណុំរឿងនូវរបាយការណ៍វេជ្ជសាស្ត្ររបស់លោកវេជ្ជបណ្ឌិត Paulus Falke និងស្នើសុំឱ្យលោក វេជ្ជបណ្ឌិតរូបនេះអាចធ្វើការផ្ដល់នូវសក្ខីកម្មតាមរយៈប្រព័ន្ធ Video Conference ក្នុងអំឡុងពេល នៃសវនាការថ្ងៃទី ២៦ កុម្ភៈ ២០០៩*។ ក្រុមមេធាវីការពារក្ដីបានបោះផ្សាយលិខិតរបស់លោកវេជ្ជ បណ្ឌិត Paulus Falke នៅលើគេហទំព័ររបស់ខ្លួនប្រហែលជានៅពេលថ្ងៃត្រង់ ថ្ងៃទី ២៣ ខែ កុម្ភៈ គឺមុនពេល ដែលអង្គបុរេជំនុំជម្រះបានធ្វើចម្លើយតបទៅទៀត (ដែលចម្លើយតបនេះត្រូវបានធ្វើនៅ ម៉ោង ១៦ ថ្ងៃដដែល)។ សេចក្ដីសម្រេចនេះត្រូវបានជូនដំណឹងនៅព្រឹកថ្ងៃទី ២៤ ខែ កុម្ភៈ គឺពីរថ្ងៃ បន្ទាប់ពីបានទទួលសំណើសុំ។ នាវេលាព្រឹកដដែលនោះ សារព័ត៌មាន *"The Cambodia Daily"* បានចុះផ្សាយលើទំព័រទីមួយនូវលិខិតរបស់លោកវេជ្ជបណ្ឌិត Paulus Falke ក្រោមចំណងជើងថា *"Ieng Sary's Health Unclear: Hague Doctor"* ។ ឆ្លងតាមរយៈពេលវេលានៃអង្គហេតុ ដូចបានរៀបរាប់ខាងលើនេះ វាមិនមែនជារឿងត្រឹមត្រូវទេចំពោះរឿងដែលថា ក្រុមមេធាវីការពារក្ដីបានធ្វើការផ្សព្វផ្សាយនូវព័ត៌មានទាំងនេះ ដើម្បីជាការឆ្លើយតបទៅនឹងការលាក់បាំងឯកសាររបស់អង្គបុរេជំនុំជម្រះ។

១៧. ការអះអាងរបស់ក្រុមមេធាវីការពារក្តី ដែលថា ឯកសារដែលបានបោះផ្សាយមិនទាក់ទងទៅនឹងខ្លឹមសារនៃកិច្ចស៊ើបសួរដែលកំពុងបន្តនេះ ប៉ុន្តែវាគ្រាន់តែទាក់ទងនឹងបញ្ហាគតិយុត្តិ វាមានលក្ខណៈមិនត្រឹមត្រូវទេ ព្រោះថា សំណើសុំយ៉ាងហោចណាស់ចំនួន០២ នៃឯកសារទាំងនោះទាក់ទងទៅនឹងសំណើសុំព័ត៌មាន (ស្តីអំពីភាពភាពទំនងជាមានភាពលំអៀង និងអាចកើតមានឡើងនៃទំនាស់ផលប្រយោជន៍) នៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលទាមទារឱ្យសហចៅក្រមស៊ើបអង្កេតបើកកិច្ចស៊ើបសួរលើបញ្ហាខ្លះៗ។

១៨. ជាចុងបញ្ចប់ ទង្វើរបស់ក្រុមមេធាវីការពារក្តី ដែលបានធ្វើការបោះផ្សាយឯកសារ *"20080702 - សារី - បណ្តឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្តីប្រឆាំងនឹងការធ្វើកោសល្យវិច័យចិត្តសាស្ត្រ"* គឺមានលក្ខណៈផ្ទុយទាំងស្រុងទៅនឹងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ២៤ កក្កដា ២០០៨[5] ដែលតាមរយៈសេចក្តីសម្រេចនេះ ឯកសារនេះមិនអាចត្រូវបានផ្សព្វផ្សាយជាសាធារណៈនោះទេ គឺត្រូវទុកជា "ការសម្ងាត់"។

១៩. យោងតាមការរៀបរាប់ទាំងអស់ខាងលើនេះ ការសម្រេចចិត្តរបស់ក្រុមមេធាវីការពារក្តីក្នុងការបោះផ្សាយឯកសារខាងលើនេះ ដែលជាការបំពានដោយផ្ទាល់ទៅលើសេចក្តីសម្រេចចុះថ្ងៃទី ១៥ ខែមករា ២០០៩ របស់សហចៅក្រមស៊ើបអង្កេត ហាមឃាត់មិនឱ្យមានការបោះផ្សាយរាល់ឯកសារសំណុំរឿង គឺជាការរំលោភលើវិធាន ៥៦(១) នៃវិធានផ្ទៃក្នុង និងមាត្រា ២១(៣) នៃកិច្ចព្រមព្រៀងចុះថ្ងៃទី ០៦ មិថុនា ឆ្នាំ ២០០៣។

២០. ការរំលោភបំពាននេះអាចត្រូវបានដាក់ទណ្ឌកម្ម តាមបទប្បញ្ញត្តិនៃវិធាន ៣៥ និង ៣៨ នៃវិធានផ្ទៃក្នុង។

[5] សេចក្តីសម្រេចទាក់ទងនឹងមាត្រា ៣.១២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ: បណ្តឹង ឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងការចាត់តាំងអ្នកជំនាញ (A189/I/6)។

ឯកសារលេខៈ ៣ 138

## ហេតុដូច្នេះ

ប្រកាសថា លោកមេធាវី Michael G.KARNAVAS និង លោកមេធាវី អាង ឧត្តម មិនបាន គោរពសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១៥ មករា ២០០៩ និងបាន រំលោភលើវិធាន ៥៦(១)នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក. ក្នុងការដែលពួកគេបានបញ្ចេញផ្សព្វផ្សាយព័ត៌ មានសម្ងាត់ និងវិធាន ២១(៣) នៃកិច្ចព្រមព្រៀង ក្នុងការដែលពួកគេមិនបានប្រព្រឹត្តទៅ ឲ្យស្របនឹង តម្លៃ និងក្រមសីលធម៌វិជ្ជាជីវៈផ្នែកយុត្តិធម៌របស់ខ្លួន។

សម្រេច៖

១. មេធាវីទាំងពីររូបត្រូវធ្វើជាបន្ទាន់នូវកិច្ចដូចខាងក្រោម៖

ក) បញ្ឈប់ការផ្សព្វផ្សាយព័ត៌មាន ឬឯកសារនានា ដែលពាក់ព័ន្ធដល់កិច្ចស៊ើបសួរ លើកលែងចំពោះបណ្ដាឯកសារទាំងឡាយណា ដែលមាននៅលើគេហទំព័ររបស់ អ.វ.ត.ក.។

ខ) ធ្វើការដកចេញនូវរាល់ឯកសារ ដែលហាមឃាត់នោះចេញពីគេហទំព័ររបស់ខ្លួន។ ប្រសិនបើឯកសារទាំងអស់នោះមិនត្រូវបានដកចេញក្នុងរយៈពេល ៤៨ ម៉ោងទេនោះ មេធាវីទាំងពីររូបនឹងត្រូវចាត់ទុកថាបានប្រព្រឹត្តការរំលោភបំពានថ្មីមួយទៀតលើ ដីកាសម្រេចនេះ។

២. ត្រូវថតចម្លងដីកានេះមួយច្បាប់ជូនដល់ស្ថាប័នដូចមានរាយនាមខាងក្រោម៖

- គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- គណៈមេធាវីសហរដ្ឋអាមេរិក
- គណៈមេធាវីរដ្ឋ Alaska



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

CO INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C.

00284976

ឯកសារ:D 138

- អង្គភាពគាំពារការការពារក្តី

ដើម្បីអាចអនុញ្ញាតឲ្យស្ថាប័នទាំងនេះធ្វើការពិចារណាលើវិធានការដែលត្រូវបន្ត។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០៩

**សហចៅក្រមស៊ើបអង្កេត**

**Co-Investigating Judges**

**Co-juges d'instruction**

យូ ប៊ុនឡេង

MARCEL Lemonde



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.